**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ឃុំជ្រោយប្រស់

សម្រាប់រយៈពេល ៣ឆ្នាំ

(ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៥ ដល់ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៨)

| | |
|---|---|
| សហគមន៍នេសាទ | : ឃុំជ្រោយប្រស់ |
| ភូមិ | : ជ្រោយប្រស់និងភូមិថ្មី |
| ឃុំ | : ជ្រោយប្រស់ |
| ស្រុក | : កោះកុង |
| ខេត្ត | : កោះកុង |

# មាតិកា

## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១-ស្ថានភាពទូទៅ**........................................១

**២-អំពីប្រជាសាស្ត្រ**........................................១

ក- ប្រជាពលរដ្ឋ ........................................១

ខ-មុខរបរ ........................................១

**៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងដែននេសាទសហគមន៍**

ក-ទីតាំង........................................២

ខ-ដែននេសាទ........................................២

គ-តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស........................................២

ឃ-ធនធានជលផល........................................២

**៤-ការធ្វើនេសាទ**........................................៣

ក-អ្នកនេសាទ........................................៣

ខ-ឧបករណ៍នេសាទ........................................៣

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ........................................៤

**៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ**........................................៥

**ក-ទស្សនៈវិស័យ**........................................៥

**ខ-គោលបំណង**........................................៥

**គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**........................................៦

គ១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ........................................៦

គ២.ផែនការបង្កើតធនាគារក្តាម........................................៦

គ៣.ផែនការល្បាតទប់ស្កាត់បទល្មើសនេសាទ........................................៧

គ៤.ផែនការពង្រឹងសមត្ថភាពគណៈកម្មការនិងសមាជិក........................................៧

គ៥.ផែនការធ្វើស្លាកសញ្ញាសហគមន៍........................................៧

**ឃ-យុទ្ធសាស្ត្រ**........................................៨

**-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល៣ឆ្នាំ**........................................៩-១០

**-តារាងកម្មវិធីការងារ**........................................១១-១២

## ១-ស្ថានភាពទូទៅ

សហគមន៍នេសាទឃុំជ្រោយប្រស់ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០២ ក្រោមការឧបត្ថម្ភបច្ចេកទេសពីខណ្ឌរដ្ឋបាលជលផលកោះកុង បរិស្ថាន និងឧបត្ថម្ភថវិកានិងសម្ភារៈពីអង្គការ DANIDA IDRC PMCR CZM UNDP និងមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ។

ចាប់តាំងពីបង្កើតសហគមន៍នេសាទក្នុងឆ្នាំ២០០២ រហូតមកដល់សព្វថ្ងៃសហគមន៍យើងខ្ញុំបានខិតខំប្រឹងប្រែងធ្វើការងារសំខាន់ៗជាច្រើនដូចជា បានចុះល្បាតបង្ក្រាបបទល្មើសជលផល និងការកាប់ព្រៃកោងកាង បានដាំកោងកាងចំនួន ៧០០០០ដើម លើផ្ទៃដី ៧ហិកតា បោះពោងព្រំប្រទល់សហគមន៍ចំនួន ១០៨ដើម បង្កើតកន្លែងអភិរក្សស្មៅសមុទ្រចំនួន ១១៦ហិកតា បោះបង្គោលបាន ១០៥៨ដើម ទម្លាក់ប្រអប់សិប្បនិម្មិតចំនួន ៥០៥ប្រអប់ សាងសង់អាងស្តុកទឹកនៅសាលារៀនចំនួន ៥០កង់។ អង្គការ CZM បានផ្តល់ទុនសម្រាប់ធ្វើកសិកម្មចំរុះមានដូចជា ចិញ្ចឹមជ្រូក គោ ក្របី មាន់ទា បណ្តុះផ្សិត ដាំបន្លែរួមផ្សំ។ បានចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាលស្តីពីសរសេររបាយការណ៍ កំណត់ហេតុ កិច្ចការរដ្ឋបាល យេនឌ័រ ជំនាញសម្របសម្រួល ប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការ ភាពជាដៃគូ គ្រប់គ្រងព្រៃលិចទឹក គ្រប់គ្រងការពារស្មៅសមុទ្រ ច្បាប់ស្តីពីជលផលនិងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ។

## ២-អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាសាស្ត្រ

-ចំនួនប្រជាពលរដ្ឋសរុប ៥៤៩គ្រួសារ ក្នុងសហគមន៍ភូមិជ្រោយប្រស់មានចំនួន ៣៦២គ្រួសារ មនុស្សសរុបចំនួន ៦៨០នាក់ ស្រីចំនួន ៣១៨នាក់ និងភូមិថ្មី ១៨៧គ្រួសារ មនុស្សសរុប ៤៤៩នាក់ ស្រី ២១៣នាក់ ក្នុងនោះមាន៖

-ជនពិការចំនួន៤៥នាក់

-អ្នកកាន់សាសនាព្រះពុទ្ធ ៥៤២គ្រួសារ យាស៊ូ ០គ្រួសារនិង អ៊ីស្លាម ៧គ្រួសារ

-ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន ....... នាក់ ស្រី .....នាក់ ។

### ខ-មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងភូមិរួមមាន៖

-ធ្វើនេសាទចំនួន ៨០% ស្មើនិង ៤៣៩គ្រួសារ

- ធ្វើស្រែចំការ ២០% ស្មើនិង ១១០គ្រួសារ

-ជាងជួសជុលម៉ូតូចំនួន ៣គ្រួសារ

-ជាងជួសជុលទូកចំនួន ៥គ្រួសារ

-ជាងសំណង់ចំនួន ១០គ្រួសារ

-ជាងជួសជុលម៉ាញ៉េទូរទស្សន៍ចំនួន ១គ្រួសារ

-លក់ដូរចំនួន ២៨គ្រួសារ

-ដឹកជញ្ជូនផលនេសាទចំនួន ៤គ្រួសារ

-ដឹកជញ្ជូនភ្ញៀវចំនួន ៤០គ្រួសារ(៤០ទូក)

-អ្នកកាប់ជ្រូក ២គ្រួសារ

-អ្នកកែច្នៃផលនេសាទចំនួន ៣០គ្រួសារ

-ម្ចាស់ផ្ទះសំណាក់ ២គ្រួសារ

- ជាងកាត់សក់ ៣គ្រួសារ

- សាឡន ២គ្រួសារ

## ៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងដែននេសាទសហគមន៍

**ក-ទីតាំង**

កន្លែងនេសាទសហគមន៍ឃុំជ្រោយប្រស់ជាដែននេសាទតំបន់ឆ្នេរសមុទ្រមានទំហំ **១១០៨៥**ហិកតានិងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់៖

-ខាងជើងទល់និងឃុំកោះកាពិ

-ខាងត្បូងទល់និងឃុំព្រែកខ្សាច់

-ខាងកើតទល់និងឃុំត្រពាំងរូង

-ខាងលិចទល់និងកោះកុងក្រៅ

**ខ-ដែននេសាទ**

កន្លែងនេសាទសហគមន៍ឃុំជ្រោយប្រស់ ជាដែននេសាទតំបន់ឆ្នេរ ។

នៅតាមដែននេសាទសហគមន៍ប្រជាពលរដ្ឋទៅរកនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទ និងរដូវនេសាទដូចខាងក្រោម៖

| ល.រ | ប្រភេទឧបករណ៍ | ទំហំ ប្រវែង/ចំនួន | ពេលវេលា រកនេសាទ | ចំនួនគ្រួសារ |
|---|---|---|---|---|
| ១ | មងក្តាម | ៦០០ម | ១ឆ្នាំ | ៤៣៩ |
| ២ | មងកាម៉ុង | ៥០០ម | ខែធ្នូ-ខែឧសភា | ៥ |
| ៣ | មងបង្គា | ៥០០ម | ១ឆ្នាំ | ១០ |
| ៤ | មងត្រីផ្ទោង | ៣០០ម | ខែវិច្ឆិកា-ខែឧសភា | ៣ |
| ៥ | មងត្រីកាឡាំង | ៥០០ម | ខែមិថុនា-ខែកញ្ញា | ៤ |
| ៦ | មងត្រីការ៉ាវ | ១០០០ម | ខែឧសភា-ខែកញ្ញា | ២ |
| ៧ | មងក្បក | ២០០ម | ១ឆ្នាំ | ១០ |
| ៨ | លបក្តាម | ៣០០ | ខែធ្នូ-ខែឧសភា | ៤៣៩ |
| ៩ | លបត្រី | ៤០ | ខែមិថុនា-ខែកញ្ញា | ១២ |
| ១០ | សន្ទូចត្រីបេកា | ១៥ផ្លែ | ខែតុលា-ខែមេសា | ៥០ |
| ១១ | សន្ទូចត្រីអង្រៃ | ១៥ផ្លែ | ខែសីហា-ខែវិច្ឆិកា | ៥០ |
| ១២ | ផ្ទាក់មឹកសំបកខ្យង | ១៥០០ខ្យង | ខែមករា-ខែមេសា | ៥ |

**គ-ធនធានជលផល**

**-ប្រភេទត្រីសមុទ្រ ៖** ត្រីស ត្រីក្បាលហែង ត្រីក្អុកស ត្រីអាំងកើយ ត្រីបេកា ត្រីតុកកែ ត្រីចាប ត្រីអង្រៃ ត្រីកិត្រីពួច ត្រីចង្កូមបី ត្រីក្តចិន ត្រីក្បក ត្រីកាម៉ុង ត្រីម្រេច ត្រីស្លង់ ត្រីផ្ទោង ត្រីឆ្លាម ត្រីប្រលួស ត្រីក្អុក ត្រីក្អុកក្បាលស្រួច ត្រីអាម៉ក់ ត្រីបបែល ត្រីអណ្តាតឆ្កែ ត្រីអួយ ត្រីកន្ទុយក្រហម ត្រីអង្រៃ ត្រីកន្ទុយបី ត្រីឆ្មារ ត្រីកំពតត្រីគោ ត្រីសមុទ្រទៃ ត្រីចាបស ត្រីចាបខ្មៅ ត្រីការ៉ាវ ត្រីត្រចៀកដំរី ត្រីដូអង្ករ ត្រីផ្ទុកសមុទ្រ ត្រីអណ្តែងប៉ុយត្រីប្រម៉ា ត្រីកន្ទុយក្របី ត្រីកន្តាំង ត្រីស្លឹកឫស្សី ត្រីកន្ទុយរឹង ត្រីអណ្តែងខ្លយ ត្រីជំឡូង ត្រីក្រាញ់សមុទ្រ..។ល។

**-ប្រភេទវារីសត្វ ៖** បង្គា ក្តាមសេះ ក្តាមថ្ម ក្តាមជំរ ក្តាមព្រលិត ក្តាមផ្តលាន់ អន្ទង់សមុទ្រ មឹក បង្កងកណ្តូប ខ្យងគ្របួន ខ្យងកំបោរ ខ្យងចាក់ច្រែង ខ្យងភ្នែកប្រើស ខ្យងដែកគោល ខ្យងដំរី ខ្យង ចំពុះទា ខ្យងផ្តិត ខ្យងចបជីក ខ្យងបន្លា ខ្យងធ្វើប្រាណ ខ្យងរៀចមាត់ ខ្យងតាឌិត ងាវកក់ ងាវ គ្រែងឈាម បង្កងប៉ាក កាំប្រម៉ា ឈ្លើងសមុទ្រ និងប្រភេទសត្វជិតផុតពូជ (ផ្សោតខ្មៅ ផ្សោតប៉ាវ៉ា បង្រ្គប បាឡាំងកាស សេះសមុទ្រ អណ្តើកសមុទ្រ ផ្កាយសមុទ្រ)។ល។

## ៤-ការធ្វើនេសាទ

### ក-អ្នកនេសាទ

-អ្នកនេសាទជាសមាជិកសហគមន៍ ចំនួន ១៨០នាក់ ស្រី ១១០នាក់

-អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍ចំនួន ៩៤៩ ស្រី ៤២១នាក់

-ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍មានចំនួន ១៧០នាក់

### ខ-ឧបករណ៍នេសាទ

-ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ

**-ឧបករណ៍នេសាទសមុទ្រ ៖**

| ល.រ | ឈ្មោះ ឧបករណ៍សាទ | ឯកតា | ចំនួន គ្រួសារ | ពេលវេលា រកនេសាទ | ទំហំ/ប្រវែង |
|---|---|---|---|---|---|
| ១ | លបក្តាម | លប | ៤៣៩ | ខែធ្នូ-ខែឧសភា | ១គ្រួសារ=៣០០ ក្រឡា ៦ស.ម ឡើង |
| ២ | មងត្រីក្បក | ម៉ែត្រ | ១២ | ១ឆ្នាំ | ១គ្រួសារ=២០០ ក្រឡា ៣.៥ ស.ម ឡើង |
| ៣ | មងក្តាម | ម៉ែត្រ | ៤៣៩ | ១ឆ្នាំ | ១គ្រួសារ=៦០០ ក្រឡា ៦ស.ម ឡើង |
| ៤ | មងត្រីកាម៉ុង | ម៉ែត្រ | ៥ | ខែធ្នូ-ខែឧសភា | ១គ្រួសារ=៥០០ ក្រឡា ៤ស.ម ឡើង |
| ៥ | មងបង្គា | ម៉ែត្រ | ១០ | ១ឆ្នាំ | ១គ្រួសារ=៥០០ ក្រឡា ៣.៨ស.ម ឡើង |
| ៦ | មងត្រីកាឡាំង | ម៉ែត្រ | ៤ | ខែមិថុនា-ខែកញ្ញា | ១គ្រួសារ=៥០០ ក្រឡា៦ស.ម ឡើង |
| ៧ | មងត្រីផ្ទោង | ម៉ែត្រ | ៣ | ខែវិច្ឆិកា-ខែឧសភា | ១គ្រួសារ=៣០០ម៉ែត្រ ក្រឡា ៥, ២សម ២ម,កំពស់១ |
| ៨ | លបត្រី | លប | ១២ | ខែមិថុនា-ខែកញ្ញា | ១គ្រួសារ=៤០ (0,៥មx១ម) |
| ៩ | ផ្ទាក់មឹកសំបកខ្យង | សំបក | ៥ | ខែមករា-ខែមេសា | ១៥០០ |
| ១០ | សន្ទូចត្រីអង្រៃ | ផ្លែ | ៥០ | ខែសីហា-ខែវិច្ឆិកា | ១គ្រួសារ=១៥ |
| ១១ | មងត្រីការ៉ាវ | ម៉ែត្រ | ២ | ខែឧសភា-ខែកញ្ញា | ១គ្រួសារ=១០០០ |
| ១២ | សន្ទូចត្រីបេកា | ផ្លែ | ៥០ | ខែតុលា-ខែមេសា | ១គ្រួសារ=១៥ |

**-ទូកកាណូតរបស់សមាជិកសហគមន៍**

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកកន្ទុយវែង | ៧១គ្រឿង | ១០០០-១៥០០គីឡូក្រាម | ៨-១៦សេះ |
| អូប៉័រមាន់ចៃ | ២៥៤គ្រឿង | ៥០០ គីឡូក្រាម | ១៣សេះ-១៥សេះ |
| ទូកមានម៉ាស៊ីនបាត | ១៧គ្រឿង | ៣ តោន ទៅ ១០ តោន | ២៤-៤៨សេះ |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មងក្លាម | ម៉ែត្រ | ៣០ទូក | ១ទូក=១០០០០ម៉ែត្រ/ ក្រឡា ៦ស.ម ឡើង |
| មងត្រីផ្ទោង | ម៉ែត្រ | ៣០ទូក | ១ទូក=៣០០ម |
| មងត្រីក្បក | ម៉ែត្រ | ១០ទូក | ១ទូក=៣០០ម |
| លបក្លាម | លប | ៥០ទូក | ១ទូក=៣០០-៦០០ លប/ ក្រឡា៦ ស.ម ឡើង |

-ទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍

| ប្រភេទទូក កាណូត | ចំនួនគ្រួសារ | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| អូប័រមាន់ចៃ | ៧៤គ្រួសារ | ១០០០ គីឡូក្រាម | ១៥សេះ |
| ទូកកន្ទុយវែង | ២០គ្រួសារ | ១០០០-១៥០០ គីឡូក្រាម | ១៦សេះ |

- ឧបករណ៍នេសាទអ្នកមកពីខាងក្រៅ
  - -លបក្លាម (កោះស្រឡៅ ឡាំដាំ) ៥០ទូក
  - -មងក្លាម (កោះស្រឡៅ ឡាំដាំ) ១៥ទូក
  - -មងត្រីក្បក (ដងទុង) ១០ទូក
  - - មងត្រីផ្ទោង (ដងទុង) ៣០ទូក

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| បង្គា | ខែមករា ដល់ ខែមិថុនា<br>១ខែ=១០ថ្ងៃ<br>១ថ្ងៃ=៣គីឡូក្រាម | ខែកក្កដា ដល់ ខែធ្នូ<br>១ខែ=៥ថ្ងៃ<br>១ថ្ងៃ=២គីឡូក្រាម | ២៤០គីឡូក្រាម/ម្នាក់ |
| ត្រីកាម៉ុង | ខែធ្នូ ដល់ ខែឧសភា<br>១ខែ=៥ថ្ងៃ<br>១ថ្ងៃ=៥គីឡូក្រាម | | ១៥០គីឡូក្រាម/ម្នាក់ |
| ត្រីអង្រែ | | ខែសីហា ដល់ ខែវិច្ឆិកា<br>១ខែ=១០ថ្ងៃ<br>១ថ្ងៃ=១០គីឡូក្រាម | ៤០០គីឡូក្រាម/ម្នាក់ |
| ត្រីកាឡាំង | | ខែមិថុនា ដល់ ខែកញ្ញា<br>១ខែ= ១០ថ្ងៃ<br>១ថ្ងៃ= ៥គីឡូក្រាម | ២០០គីឡូក្រាម/ម្នាក់ |
| ត្រីក្បក | ១ខែ=២០ថ្ងៃ<br>១ថ្ងៃ=១០គីឡូក្រាម | ១ខែ=២០ថ្ងៃ<br>១ថ្ងៃ=១៥គីឡូក្រាម | ៣០០០គីឡូក្រាម/ម្នាក់ |

| | | | |
|---|---|---|---|
| ក្តាមសេះ (លប) | ខែធ្នូ ដល់ ខែឧសភា<br>១ខែ=២០ថ្ងៃ<br>១ថ្ងៃ=៥គីឡូក្រាម | | ៦០០គីឡូក្រាម/ម្នាក់ |
| ក្តាមសេះ (មង) | ខែធ្នូ ដល់ ខែឧសភា<br>១ខែ=១៥ ថ្ងៃ<br>១ថ្ងៃ=៣គីឡូក្រាម | | ២៧០គីឡូក្រាម/ម្នាក់ |
| ក្តាមថ្ម(លប) | | ខែមិថុនា ដល់ ខែវិច្ឆិកា<br>១ខែ=១០ ថ្ងៃ<br>១ថ្ងៃ=៣ គីឡូក្រាម | ១៨០គីឡូក្រាម/ម្នាក់ |
| ត្រីការ៉ាវ | | ខែមិថុនា ដល់ ខែកញ្ញា<br>១ខែ=៤ថ្ងៃ<br>១ថ្ងៃ=៤គីឡូក្រាម | ៦៤គីឡូក្រាម/ម្នាក់ |
| មងត្រីផ្ទោង | ខែធ្នូ ដល់ ខែឧសភា<br>១ខែ=៥ថ្ងៃ<br>១ថ្ងៃ=៥គីឡូក្រាម | | ១៥០គីឡូក្រាម/ម្នាក់ |
| មឹក | ខែមករា ដល់ ខែមេសា<br>១ខែ=៨ថ្ងៃ<br>១ថ្ងៃ=៨០គីឡូក្រាម | | ២៥៦គីឡូក្រាម/ម្នាក់ |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

**ក-ទស្សនៈវិស័យ**

សហគមន៍នេសាទឃុំជ្រោយប្រស់មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

**ខ-គោលបំណង**

-ចូលរួមគ្រប់គ្រងដែននេសាទ កន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង និងកន្លែងនេសាទតាមឆ្នេរ។

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម។

-ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

**គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

**គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលារកនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | |
|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួនគ្រួសារ |
| ដែននេសាទ ព្រែកខៀន | ពេញ ១ ឆ្នាំ | លបក្តាមថ្ម | ក្រឡា ៦ស.ម ឡើង | ១០ |
| | ពេញ១ឆ្នាំ | ឆ្នុះបង្គា | | ៨ |
| | ១ឆ្នាំ | មងត្រីក្បក | ក្រឡា៣.៥ ស.ម ឡើង/៥០០ ម៉ែត្រ | ៥ |
| ដែននេសាទព្រៃតាទី | ១ឆ្នាំ | ត្រីក្បក | ក្រឡា៣.៥ ស.ម ឡើង/៥០០ ម៉ែត្រ | ៥ |
| | ១ឆ្នាំ | ឆ្នុះបង្គា | | ១៥ |
| | ១ឆ្នាំ | លបក្តាមថ្ម | ក្រឡា ៦ស.ម ឡើង | ១០ |
| ដែននេសាទជ្រោយប្រស់ | ១ឆ្នាំ | មងក្តាម | ៦០០ម | ៤៣ |
| | ខែធ្នូ-ខែឧសភា | មងកាម៉ុង | ៥០០ម | ៥ |
| | ១ឆ្នាំ | មងបង្គា | ៥០០ម | ១០ |
| | ខែវិច្ឆិកា-ខែឧសភា | មងត្រីផ្ទោង | ៣០០ម | ៣ |
| | ខែមិថុនា-ខែកញ្ញា | មងត្រីកាឡាំង | ៥០០ម | ៤ |
| | ខែឧសភា-ខែកញ្ញា | មងត្រីការ៉ាវ | ១០០០ម | ២ |
| | ១ឆ្នាំ | មងក្បក | ២០០ម | ១០ |
| | ខែធ្នូ-ខែឧសភា | លបក្តាម | ៣០០ | ៤៣ |
| | ខែមិថុនា-ខែកញ្ញា | លបត្រី | ៤០ | ១២ |
| | ខែតុលា-ខែមេសា | សន្ទូចត្រីបេកា | ១៥ផ្លែ | ៥០ |
| | ខែសីហា-ខែវិច្ឆិកា | សន្ទូចត្រីអង្រែ | ១៥ផ្លែ | ៥០ |
| | ខែមករា-ខែមេសា | ផ្ទាក់មឹកសំបកខ្យង | ១៥០០ខ្យង | ៥ |

**គ២-ផែនការរៀបចំធនាគារក្តាម**

ផែនការរៀបចំធនាគារក្តាម និងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍ | ៤ម×៤ម | បែរបោះបង្គោល | ទិញសាច់អួនចំនួន ៣០គីឡូក្រាម | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ ២០២៥ |
| | | | ទិញបង្គោលចំនួន ១៥ដើម | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ ២០២៥ |
| | | | ទិញខ្សែចងចំនួន ១២គីឡូក្រាម | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ ២០២៥ |

**គ៣-.ផែនការល្បាតទប់ស្កាត់បទល្មើសនេសាទ**

ដើម្បីគ្រប់គ្រង ថែរក្សា ការពារ អភិវឌ្ឍធនធានធម្មជាតិ ជាពិសេសធនធានជលផលឱ្យមានភាពល្អប្រសើរ និងមាននិរន្តរភាព សហគមន៍នេសាទមានផែនការពង្រឹងចុះល្បាតក្នុងកន្លែងនេសាទសហគមន៍ឱ្យបានជាប្រចាំ ។ ផែនការសម្រាប់ពង្រឹងការងារចុះល្បាតឲ្យមានប្រសិទ្ធភាព នឹងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|
| រៀបចំកម្មវិធីនិងបែងចែកក្រុមល្បាត | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |
| ទិញប្រេងសាំងសម្រាប់ល្បាតចំនួន ១៥០លីត្រ/ខែ | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៨ |
| ទិញប្រេងលាយ ៦ដប/ខែ | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៨ |
| ទិញសម្ភារៈល្បាត<br>- អាវភ្លៀង ១២អាវ<br>- អាវពោង ១២<br>- ពិល ១២<br>- កៅឡាក់១ | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |
| ចុះល្បាតចំនួន ៦ដង/ខែ | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៨ |

**គ៤-ផែនការពង្រឹងសមត្ថភាពដល់គណៈកម្មការ និងសមាជិកសហគមន៍**

ផែនការពង្រឹងសមត្ថភាពដល់គណៈកម្មការ និងសមាជិកសហគមន៍ នឹងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|
| បណ្តុះបណ្តាលស្តីពីកម្មវិធីស្មាត (SMART) ចំនួន ៣វគ្គ | ត្រីមាសទី២ ឆ្នាំ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |
| បណ្តុះបណ្តាលវិធីសាស្រ្តក្នុងការចុះល្បាត១វគ្គ | ត្រីមាសទី២ ឆ្នាំ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |
| បណ្តុះបណ្តាលជំនាញសម្របសម្រួល និងដោះស្រាយទំនាស់ | ត្រីមាសទី១ ឆ្នាំ២០២៦ | ត្រីមាសទី១ ឆ្នាំ២០២៦ |
| បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ១វគ្គ | ត្រីមាសទី៣ ឆ្នាំ២០២៥ | ត្រីមាសទី៣ ឆ្នាំ២០២៥ |
| បណ្តុះបណ្តាលច្បាប់ជលផល លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ១វគ្គ | ត្រីមាសទី៣ ឆ្នាំ២០២៥ | ត្រីមាសទី៣ ឆ្នាំ២០២៥ |
| បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ត្រីមាសទី៣ ឆ្នាំ២០២៥ | ត្រីមាសទី៣ ឆ្នាំ២០២៥ |

**គ៥-ផែនការរៀបចំធ្វើស្លាកសញ្ញា**

ផែនការរៀបចំធ្វើស្លាកសញ្ញា និងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ទំហំ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|
| ១.៥ម×១ម | ធ្វើស្លាកសញ្ញាផែនទីសហគមន៍ ចំនួន ១ផ្ទាំង | ត្រីមាសទី២ ឆ្នាំ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |
| ១.៥ម×១ម | ធ្វើស្លាកសញ្ញាឧបករណ៍នេសាទនេសាទខុសច្បាប់ចំនួន ១ផ្ទាំង | ត្រីមាសទី២ ឆ្នាំ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |

ឃ-យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម ៖

-បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមាន សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍និងចំណេះដឹងល្អៗជាពិសេសបញ្ហានេសាទ។

-ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណា ដែលទាក់ទងនិងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម ។

-រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ ។

-រៀបចំផែនការអនុវត្តផែនការតាមដំណាក់កាលនិមួយៗដោយជាក់លាក់ ។

-ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិការ និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ ។

-ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ ។

-គៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ ។

-រៀបចំវិធានការណ៍ចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍ ។

-ពង្រឹងសមត្ថភាពបច្ចេកទេស និង គ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ ។

-ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ ។

-បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឃុំជ្រោយប្រស់រយៈពេល ៣ឆ្នាំ**
**(ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៥ ដល់ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៨)**

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ(រៀល) | ប្រភពជំនួយ | ពេលចាប់ផ្តើម | ពេលបញ្ចប់ |
|---|---|---|---|---|---|---|
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | រៀបចំឯកសាផ្សព្វផ្សាយ | -ផលស្តុកមាននិរន្តរភាពក្នុងសហគមន៍ | ២០០,០០០ | | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |
| | ប្រជុំផ្សព្វផ្សាយដល់សមាជិកពីការប្រើប្រាស់ឧបករណ៍នេសាទ និងទីកន្លែងនៅក្នុងដែនសហគមន៍១ដង/ឆ្នាំ | | ១,២០០,០០០ | | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៨ |
| | ប្រជុំផ្សព្វផ្សាយដល់អ្នកនេសាទមកពីខាងក្រៅ ១ដង/ឆ្នាំ | | ១,២០០,០០០ | | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៨ |
| គ២-ផែនការបង្កើតធនាគារក្តាម | ទិញសាច់អួនចំនួន ៣០គីឡូក្រាម | -ធនធានក្តាមសេះមានការកើនឡើង | ២,១០០,០០០ | | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |
| | ទិញបង្គោលចំនួន ១៥ដើម | -អ្នកនេសាទទួលបានផលចាប់ក្តាមច្រើនជាងមុន | ៤៥០,០០០ | | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |
| | ទិញខ្សែចងចំនួន ១២គីឡូក្រាម | -ប្រជាពលរដ្ឋទទួលបានចំណូលប្រសើរឡើង | ២៤០,០០០ | | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |
| គ៣-ផែនការល្បាតទប់ស្កាត់បទល្មើសនេសាទ | រៀបចំកម្មវិធី និងបែងចែកក្រុមល្បាត | -បទល្មើសជលផលមានការថយចុះ<br>-ក្រុមល្បាតបានយល់ដឹងពីនីតិ វិធីទប់ស្កាត់ល្មើស | ០ | | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |
| | ទិញប្រេងសាំងសម្រាប់ល្បាតចំនួន ១៥០លីត្រ/ខែ | | ២៧,០០០,០០០ | | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៨ |
| | ទិញប្រេងលាយ ៦ដប/ខែ | | ៥,៤០០,០០០ | | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៨ |
| | ទិញសម្ភារៈល្បាត<br>- អាវភ្លៀង ១២អាវ<br>- អាវពោង ១២ | | ៤៨០០០០<br>៧២០០០០ | | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |

| | | | | | | |
|---|---|---|---|---|---|---|
| | - ពិល ១២<br>-កៅឡាក់១ | | ៣០០០០០<br>២៤០០០០ | | | |
| | ចុះល្បាតចំនួន ៦ដង/ខែ (ផ្តល់អាហារល្បាត) | | ២៥,៩២០,០០០ | | ត្រីមាសទី១ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៨ |
| **គ៤-ផែនការពង្រឹងសមត្ថភាពដល់គណៈកម្មការ និងសមាជិកសហគមន៍** | បណ្តុះបណ្តាលស្តីពីកម្មវិធីស្មាត (SMART) ចំនួន ៣វគ្គ | -សមត្ថភាពគណៈកម្មការមានការកើនឡើង<br>-សមាជិកមានការយល់ដឹង | ៩,៦០០,០០០ | | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |
| | បណ្តុះបណ្តាលវិធីសាស្រ្តក្នុងការចុះល្បាត១វគ្គ | | ៣,២០០,០០០ | | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |
| | បណ្តុះបណ្តាលជំនាញសម្របសម្រួល និងដោះស្រាយទំនាស់ | | ៣,២០០,០០០ | | ត្រីមាសទី១ ឆ្នាំ ២០២៦ | ត្រីមាសទី១ ឆ្នាំ២០២៦ |
| | បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ១វគ្គ | | ៣,២០០,០០០ | | ត្រីមាសទី៣ ឆ្នាំ ២០២៥ | ត្រីមាសទី៣ ឆ្នាំ២០២៥ |
| | បណ្តុះបណ្តាលច្បាប់ជលផល លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ១វគ្គ | | ៣,២០០,០០០ | | ត្រីមាសទី៣ ឆ្នាំ ២០២៥ | ត្រីមាសទី៣ ឆ្នាំ២០២៥ |
| | បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | | ៣,២០០,០០០ | | ត្រីមាសទី៣ ឆ្នាំ ២០២៥ | ត្រីមាសទី៣ ឆ្នាំ២០២៥ |
| **គ៥-ផែនការរៀបចំធ្វើស្លាកសញ្ញា** | ធ្វើស្លាកសញ្ញាផែនទីសហគមន៍ចំនួន ១ផ្ទាំង | -ប្រជាពលរដ្ឋមានការយល់ដឹង<br>-អ្នកនេសាទមកពីខាងក្រៅមានការយល់ដឹង | ១,០០០,០០០ | | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |
| | ធ្វើស្លាកសញ្ញាឧបករណ៍នេសាទនេសាទខុសច្បាប់ចំនួន ១ផ្ទាំង | | ១,០០០,០០០ | | ត្រីមាសទី២ ឆ្នាំ ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៥ |
| **សរុបថវិកាចំណាយរួម** | | | **៩៣,០៥០,០០០** | | | |

## តារាងកម្មវិធីការងារ

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២៥ | | | | | | | ២០២៦ | | | | | | | | | | | | ២០២៧ | | | | | | | | | | | | ២០២៨ | | | | |
| | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ |
| **គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.១ រៀបចំឯកសារផ្សព្វផ្សាយ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.២ ប្រជុំផ្សព្វផ្សាយដល់សមាជិកពីការប្រើប្រាស់ឧបករណ៍នេសាទ និងទីកន្លែងចំនួន ១ដង/ឆ្នាំ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | | | | ■ | ■ |
| ១.៣ ប្រជុំផ្សព្វផ្សាយដល់អ្នកនេសាទមកពីខាងក្រៅ ១ដង/ឆ្នាំ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | | | | ■ | ■ |
| **គ២-ផែនការបង្កើតធនាគារក្តាម** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.១ ទិញសាច់អួនចំនួន៣០គីឡូក្រាម | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.២ ទិញបង្គោលចំនួន១៥ដើម | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.៣ ទិញខ្សែចងចំនួន ១២គីឡូក្រាម | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **គ៣-ផែនការល្បាតទប់ស្កាត់បទល្មើសនេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.១ រៀបចំកម្មវិធី និងបែងចែកក្រុមល្បាត | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.២ ទិញប្រេងសាំងសម្រាប់ល្បាត ១៥០លីត្រ/ខែ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៣.៣ ទិញប្រេងលាយ ៦ដប/ខែ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៣.៤ ទិញសម្ភារៈល្បាត | ■ | | | | | | | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | |
| ៣.៥ ចុះល្បាត ៦ដង/ខែ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| **គ៤-ផែនការពង្រឹងសមត្ថភាពដល់គណៈកម្មការ និងសមាជិកសហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| | |
|---|---|
| ៤.១ បណ្តុះបណ្តាលស្តីពីកម្មវិធីស្មាត (SMART) ចំនួន ៣វគ្គ | |
| ៤.២ បណ្តុះបណ្តាលវិធីសាស្រ្តក្នុងការចុះល្បាត១វគ្គ | |
| ៤.៣ បណ្តុះបណ្តាលជំនាញសម្របសម្រួល និងដោះស្រាយទំនាស់ | |
| ៤.៤ បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ១វគ្គ | |
| ៤.៥ បណ្តុះបណ្តាលច្បាប់ផលផល លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ១វគ្គ | |
| ៤.៦ បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | |
| **គ៥-ផែនការរៀបចំធ្វើស្លាកសញ្ញា** | |
| ៥.១ ធ្វើស្លាកសញ្ញាផែនទីសហគមន៍ចំនួន ៤១ | |
| ៥.២ ធ្វើស្លាកសញ្ញាឧបករណ៍នេសាទនេសាទខុសច្បាប់ចំនួន ១ | |

**បានឃើញ និងគោរពជូន**
លោកនាយខណ្ឌរដ្ឋបាលជលផលកោះកុង
" <u>ដើម្បីជូនពិនិត្យ និងសម្រួល</u>"
ថ្ងៃ.........ខែ.........ឆ្នាំ.........ព.ស.២៥៦៨
ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០២៤......
**នាយផ្នែករដ្ឋបាលជលផលពាមក្រសោប**

លេខ: .........
**បានឃើញ និងគោរពជូន**
លោកនាយផ្នែករដ្ឋបាលជលផលពាមក្រសោប
" <u>ដើម្បីជូនពិនិត្យ និងសម្រួល</u>"
ថ្ងៃ.........ខែ.........ឆ្នាំ.........ព.ស.២៥៦៨
ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០២៤...
**មេឃុំជ្រោយប្រស់**

**ពុំ ធឿន**

**សូមគោរពជូន**
លោកមេឃុំជ្រោយប្រស់
" <u>ដើម្បីជូនពិនិត្យ និងសម្រួល</u>"
ថ្ងៃ.........ខែ.........ឆ្នាំ.........ព.ស.២៥៦៨
ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០២៤...
**ប្រធានគណៈកម្មការសហគមន៍នេសាទឃុំជ្រោយប្រស់**

លេខ: .........
**<u>បានឃើញ និងគោរពជូន</u>**
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល
" <u>ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ</u>"
ថ្ងៃ.........ខែ.........ឆ្នាំ.........ព.ស.២៥៦៨...
ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០២៤.....
**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្តកោះកុង**

**អែម សុធារ៉ា**

**បានឃើញ និងគោរពជូន**
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្តកោះកុង
" ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ.........ខែ.........ឆ្នាំ.........ព.ស.២៥៦៨
ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០២៤...
**នាយខណ្ឌរដ្ឋបាលជលផលកោះកុង**

លេខ: .........
**<u>បានឃើញ និងឯកភាព</u>**
ថ្ងៃ.........ខែ.........ឆ្នាំ.........ព.ស.២៥៦៨
រាជធានីភ្នំពេញ.ថ្ងៃទី ៧ ខែ ខុសភា ឆ្នាំ២០២៤......
**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**ពុំ សុថា**